អង្គការអប់រំពិភពលោក
WORLD EDUCATION

# គម្រោងស្បៀងអាហារសម្រាប់ការអប់រំ

# បណ្ណែណែនាំអំពីរបៀបដឹកនាំ ការអានរឿង

## ការសិក្សាស្រាវជ្រាវ

កុមាររៀនដោយយកចិត្តទុកដាក់តាមរយៈការស្ដាប់រឿង និងជាញឹកញយពួកគេយកចិត្តទុកដាក់ល្បះមួយចំនួនជាក់លាក់ បើទោះបីពួកគេមិនអាចអានល្បះទាំងនោះបានក៏ដោយ។ សាច់រឿងដែលមានពាក្យឬឃ្លាដដែលគឺមានសារៈសំខាន់ណាស់សម្រាបពួកគេ។ កុមារតូចៗបានឮ និងព្យាយាមឲ្យពួកគេរៀនពីល្បះ និងប្រយោគវែងៗបន្ថែមទៀត។ ទាំងអស់នេះគឺជាប់ពាក់ព័ន្ធការអភិវឌ្ឍចំណេះដឹងផ្នែកខាងវេយ្យករណ៍ ដែលធ្វើឲ្យអត្ថន័យរបស់វាកាន់តែច្បាស់លាស់។ កុមារពង្រីកចំណេះរបស់ពួកគេដឹងលើពាក្យ និងយល់ពីពាក្យទាំងនោះតាមរយៈការស្ដាប់រឿង។

## សេចក្ដីណែនាំសម្រាប់ការអានរឿង

ខាងក្រោមគឺជាដំបូន្មានមួយចំនួនសំរាប់ធ្វើការអានរឿងទៅកុមារ។

ការរៀបចំ:

❖ សម្រេចថាតើសៀវភៅរឿងមួយណាដែលអ្នកយកទៅអាន ដែលសមនិងអាយុកុមារបំផុត។

- ធ្វើការអានរឿងដោយខ្លួនឯងពីទៅបីដង ដើម្បីឲ្យប្រាកដថាអ្នកបានយល់សាច់រឿងនោះបានច្បាស់លាស់។
- គិតអំពីសំឡេងតួអង្គ និងកាយវិកាដើម្បីជួយឲ្យសាច់រឿងមានភាពកាន់តែរស់រវើក។
- គិតអំពីពាក្យពិបាកដែលអ្នកនិងត្រូវពន្យល់ទៅកាន់សិស្ស។
- រៀបចំសំណួរដើម្បីសួរកុមារបន្ទាប់ពីអានរឿងចប់។
- គិតអំពីសកម្មភាពបន្ថែមដែលអ្នកនិងឲ្យកុមារអនុវត្ត។

## មុនពេលអានរឿង:

- គិតអំពីទីតាំងដែលកុមារត្រូវអង្គុយ។ ឲ្យពួកគេរំកិលមកមុខ និងអង្គុយលើកន្ទេលអាចមើលឃើញរូបភាពច្បាស់។ ឲ្យសិស្សអង្គុយចុះជាវិធីងាយស្រួលជួយឲ្យសិស្សឃើញសៀវភៅច្បាស់។
- សូមប្រាប់ពួកគេអំពីអ្វីដែលអ្នកត្រូវធ្វើ និងតើពួកគេត្រូវមានអកប្បកិរិយារបៀបណា ជាឧទាហរណ៍អ្នកចង់ឲ្យពួកគេស្តាប់ដោយយកចិត្តទុកដាក់ ឬចូលរួមនៅត្រង់ចំនុចនានានៃរឿង។
- ប្រសិនបើអាចប្រាប់ពួកគេអំពីអ្វីដែលត្រូវឲ្យពួកគេធ្វើនៅចង់បញ្ចប់នៃរឿង ជាឧទាហរណ៍អ្នកអាចសួរសំណួរពួកគេ ឬឲ្យពួកគេសង្ខេបរឿងឡើងវិញជាដើម។

## ការអានរឿង:

- ណែនាំអំពីចំណងជើងរឿង និងឈ្មោះអ្នកនិពន្ធ
- សម្រាកបន្តិច រួច ញញឹម
- ប្រើក្រសែភ្នែកសំឡឹងទៅកុមារដោយការទាក់ទាញ
- អានរឿងឲ្យបានច្បាស់ៗ និងមានការលើកដាក់សំឡេងសមរម្យ

- មានការពន្យល់ពាក្យពិបាក
- កាន់សៀវភៅយ៉ាងណាឲ្យកុមារទាំងអស់អាចមើលឃើញរូបភាព
- ប្រសិនបើរឿងនោះខ្លី បើមានពេលអ្នកគួអានរឿងឲ្យបានពីរដង ។

អនុវត្តដូចខាងក្រោមនេះ

- នៅចុងបញ្ចប់នៃការអានរឿង
  សួរកុមារថាតើពួកគេមានភាពសប្បាយរីករាយជាមួយនិងសាច់រឿង។
- លើកទឹកចិត្តកុមារឲ្យជជែកអំពីរឿងដោយសួរសំណួរ
  សំណួរខ្លះជាសំណួរបិទដើម្បីចង់ដឹងពីការចងចាំរបស់កុមារ
  សំណួរខ្លះគួរជាសំណួរបើក
  ដើម្បីចង់ដឹងពីការយល់របស់កុមារលើសាច់រឿងបានប៉ុណ្ណា។
- ណែនាំពីសកម្មភាពដូចខាងក្រោម

វីដេអូខាងក្រោមនេះ គ្រូនិងអានរឿង (យូពី) ទៅកុមារថ្នាក់ទី១ ជាមួយនិងសកម្មភាពសំណួរដើម្បីយល់ន័យ។

**ការអានរឿង**

សូមចូលមើល(វីដេអូ)តាមរើបសាយខាងក្រោម :

https://youtu.be/IDUWuDomimU

